# គំរូនៃគោលនយោបាយ

## សេចក្ដីថ្លែងការណ៍ពគោលនយោបាយជ្រើសរើសបុគ្គលិកប្រកបដោយការទទួលខុសត្រូវ

### ការប្ដេជ្ញាចិត្តចំពោះគោលការណ៍ជ្រើសរើសបុគ្គលិកដោយយុត្តិធម៌ និងការទទួលខុសត្រូវ

ក្រុមហ៊ុនរបស់យើងប្ដេជ្ញាប្រកាន់ខ្ជាប់នូវគោលការណ៍ និងធ្វើការជ្រើសរើសបុគ្គលិកដោយយុត្តិធម៌ និងប្រកបដោយការទទួលខុសត្រូវ ដែលគោរព ការពារ និងបំពេញនូវសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ រួមទាំងការបញ្ជាក់នៅក្នុងស្តង់ដារច្បាប់ការងារអន្តរជាតិ ជាពិសេសសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម និងការចរចាជាសមូហភាព ការទប់ស្កាត់ និងលុបបំបាត់ពលកម្មដោយបង្ខិតបង្ខំ។ ពលកម្មកុមារ និងការរើសអើង នៅគ្រប់ជំហាននៃដំណើរការជ្រើសរើស និងការជួលបុគ្គលិក។

ក្រុមហ៊ុនរបស់យើងទទួលស្គាល់ថាការជ្រើសរើសបុគ្គលិកគួរតែឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ។ គួរតែផ្អែកលើគុណវុឌ្ឍិ មិនគួរប្រើប្រាស់កម្លាំងពលកម្មដែលស្រាប់ខុសគោលដៅ ដោយសារតែ ស្តង់ដារការងារទាប ប្រាក់ឈ្នួល ឬលក្ខខណ្ឌការងារ ឬបំផ្លាញការងារបានដែរនោះទេ។ ទោះបីជាក្រុមហ៊ុនធ្វើការជ្រើសរើសបុគ្គលិកក្នុងស្រុក ឬជ្រើសរើសកម្មករឆ្លងដែននោះទេ យើងទាមទារឱ្យមានការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាតិជាធរមាន។ តម្លាភាពសម្រាប់ភាគីពាក់ព័ន្ធទាំងអស់ ការការពារសម្រាប់កម្មករពេញមួយដំណើរការជ្រើសរើស និងការងារ រួមទាំងសិទ្ធិដឹងអំពីសិទ្ធិរបស់ពួកគេ សេរីភាពនៃការធ្វើដំណើរក្នុងប្រទេសថៃ ឬចាកចេញពីប្រទេសថៃ។ ការគ្រប់គ្រងផ្ទាល់ខ្លួននៃឯកសារអត្តសញ្ញាណនិងកិច្ចសន្យារបស់ពួកគេ និងការទទួលបានយន្តការដោះស្រាយបណ្តឹងសារទុក្ខ និងវិវាទ ព្រមទាំងទទួលបានដំណោះស្រាយដែលសមស្រប។

ក្រុមហ៊ុនរបស់យើងចាត់ទុកគោលនយោបាយនេះថាមានសារៈសំខាន់ក្នុងការទប់ស្កាត់ហានិភ័យការងារដែលមានបណ្ដាលមកពីដំណើរការនៃការជ្រើសរើសបុគ្គលិក ពលករ ជាពិសេសពលករចំណាកស្រុកដែលនឹងត្រូវប្រឈមមុខនឹងហានិភ័យនៃការកេងប្រវ័ញ្ច ដោយចាប់ផ្តើមពីប្រទេសកំណើតរបស់ពួកគេ មុនពេលពួកគេទៅដល់រោងចក្រ។ ពួកគេងាយរងគ្រោះនៅពេលដំណើរការនៃការជ្រើសរើសបុគ្គលិកដែលមានការបោកបញ្ឆោត ឬក្លែងបន្លំ ដែលកម្រកើតមាននៅក្នុងក្រុមហ៊ុនយើងណាស់ ប៉ុន្តែក្រុមហ៊ុនបាត់បង់ភាគច្រើនពីផលប៉ះពាល់ដល់ម៉ាកយីហោ កេរ្តិ៍ឈ្មោះ អតិថិជន និងលទ្ធភាពអាជីវកម្មរបស់យើង ដែលបណ្តាលមកពីការជ្រើសរើសបុគ្គលិកដែលមិនទទួលខុសត្រូវ និងខុសច្បាប់ដោយភាគីពាក់ព័ន្ធណាមួយ នៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់របស់យើង។ ដូច្នេះហើយ តាមរយៈគោលនយោបាយនេះ និងការអនុវត្តរបស់ខ្លួន ក្រុមហ៊ុនបានធ្វើការប្ដេជ្ញាចិត្តក្នុងការធ្វើឱ្យមានភាពប្រសើរឡើង ដើម្បីលើកទឹកចិត្តឱ្យមានការកែលម្អជាបន្តបន្ទាប់នៃការអនុវត្តជ្រើសរើសបុគ្គលិកប្រកបដោយការទទួលខុសត្រូវ។ ក្រុមហ៊ុនជឿជាក់ថា តាមរយៈយុទ្ធសាស្ត្រនេះ ក្រុមហ៊ុនអាចជួយកាត់បន្ថយ សម្រាល និង/ឬលុបបំបាត់ហានិភ័យនៃការកេងប្រវ័ញ្ច និងការរំលោភបំពានសម្រាប់អ្នកស្វែងរកការងារ និងកម្មករនិយោជិតក្នុងអំឡុងពេលដំណើរការជ្រើសរើស។ ដូច្នេះហើយអាចឱ្យមនុស្សទាំងអស់ រួមទាំងស្ត្រីទទួលបានការងារសមរម្យ និងប្រាក់ចំណូលនៅក្នុងបរិយាកាសដែលមានការការពារ និងគាំទ្រ ដែលអាចអនុញ្ញាតឱ្យពួកគេសម្រេចបាននូវសក្តានុពលការងារពេញលេញរបស់ពួកគេ។

## តំបន់ដែលមិនមានការលើកលែង

ក្រុមហ៊ុនរបស់យើងប្រកាន់ជំហររឹងមាំប្រឆាំងនឹងគ្រប់ទម្រង់ ការសំដែង ការចង្អុលបង្ហាញ និងភស្តុតាងនៃការប្រព្រឹត្តអំពើអមនុស្សធម៌ទាក់ទងនឹងការជួញដូរមនុស្ស។ បង្ខំ បង្ខាំងឱ្យធ្វើការសងបំណុល ទាសករ កិច្ចសន្យា ពលកម្មកំហិតដោយចេតនា ពលកម្មកុមារ ការរើសអើងភេទ ពូជសាសន៍ សាសនា ជាតិសាសន៍ ទំនោរផ្លូវភេទ ពិការភាព និងផ្សេងៗ។ សិទ្ធិសេរីភាព ឬសមាគម និងការចរចាជាសមូហភាព ក៏ដូចជាការអនុវត្តណាមួយដែលអាចប៉ះពាល់ដល់អាយុជីវិត សុខភាព សុវត្ថិភាព និងសេចក្តីថ្លៃថ្នូររបស់អ្នកស្វែងរកការងារ និងកម្មករ។ ក្រុមហ៊ុនរបស់យើងចាត់ទុកទង្វើបែបនេះថាមិនអាចអត់ឱនឬលើកលែងឱ្យបានព្រោះជាទង្វើរគ្មានសីលធម៌ និងខុសច្បាប់។ ដូច្នេះយើងនឹងចាត់វិធានការចំពោះជនល្មើស ដែលដឹងថាវាអំពើបង្កគ្រោះថ្នាក់ ឬកន្លែងបង្កគ្រោះថ្នាក់ដល់កម្មករនិយោជិតជាពិសេសភាគីពាក់ព័ន្ធដែលងាយរងគ្រោះដូចជាស្ត្រី និងកុមារី ដោយបង្កើតបន្ទុកបំណុល ការបាត់បង់សេរីភាព ការបម្រើការងារដោយមិនពេញចិត្ត ហានិភ័យផ្លូវកាយ និងផ្លូវចិត្តដែលអាចបង្កជាការខូចខាត រប្ួសរយៈពេលខ្លីឬវែងដល់ជីវិត ទ្រព្យសម្បត្តិ សុខុមាលភាព ក៏ដូចជាឱកាស និងសមត្ថភាពបំពេញការងារ និងរកប្រាក់ចំណូលសមរម្យរបស់ពួកគេ។

## ភាពអាចអនុវត្តបាន និងវិសាលភាព

ក្រុមហ៊ុន និងនិយោជិតទាំងអស់របស់យើងនឹងមិនចូលរួម លើកទឹកចិត្ត គាំទ្រ ឬការដោះសារ - ដោយផ្ទាល់ ឬដោយប្រយោល - រាល់ការរំលោភលើសិទ្ធិមនុស្ស និងសិទ្ធិជាមូលដ្ឋានរបស់កម្មករ ដូចដែលបានកំណត់ក្នុងស្តង់ដារការងារអន្តរជាតិស្នូលទាំងបួនរបស់ ILO (ផ្អែកលើស្នូលទាំង8នៃអនុសញ្ញា ILO) និងបានកំណត់នៅក្នុងគោលនយោបាយផ្សេងទៀតរបស់យើងពីស្នូលនីមួយៗច្បាប់ការងារ។ ជាមួយគ្នានេះ ក្រុមហ៊ុនប្តេជ្ញាមិនធ្វើអាជីវកម្មជាមួយបុគ្គល ឬស្ថាប័នណាមួយឡើយ ជាពិសេសអ្នកជ្រើសរើសពលករ និងភ្នាក់ងារជ្រើសរើសបុគ្គលិកនិយោជិត ដែលត្រូវបានជាប់ពាក់ព័ន្ធ សង្ស័យ ចោទប្រកាន់ ឬបង្ហាញឱ្យឃើញលើសពីការសង្ស័យថាបានរំលោភលើសិទ្ធិមនុស្ស និងសិទ្ធិជាមូលដ្ឋានរបស់កម្មករនិយោជិត ជាពិសេសការចូលរួមក្នុងការជួញដូរមនុស្ស ការប្រើប្រាស់ពលកម្មកុមារ បង្ខិតបង្ខំ ឃុំឃាំងឱ្យធ្វើការសងបំណុល ទាសករ កិច្ចសន្យា ការធ្វើការងារដោយមិនពេញចិត្ត ការបៀតបៀនផ្លូវភេទឬការកេងប្រវ័ញ្ចផ្លូវភេទ នៅក្នុងប្រតិបត្តិការ ឬសង្វាក់ផ្គត់ផ្គង់។ ជាពិសេស យើងនឹងមិនទិញសម្ភារៈ ឬសេវាកម្មពីអ្នកផ្គត់ផ្គង់ អ្នកម៉ៅការបន្ត អ្នកផ្តល់សេវា ឈ្មួញកណ្តាល ភ្នាក់ងារ រួមទាំងអ្នកជ្រើសរើសកម្មករនិយោជិត ដែលអាចមានឬជាប់ពាក់ព័ន្ធជាមួយអំពើអសីលធម៌ និងខុសច្បាប់ដែលបានរៀបរាប់ខាងលើជាដាច់ខាត។

ក្រុមហ៊ុនរបស់យើងនឹងមិនប្រើប្រាស់កម្លាំងដោយការដាក់ទណ្ឌកម្ម ឬវិធានការពិន័យសម្រាប់កម្មករដែលបង្ហាញពីទស្សនៈរបស់ពួកគេ ឬទំនាក់ទំនងជាមួយកម្មករផ្សេងទៀតឡើយ។ ដែលវាមានន័យថាជារើសអើងភេទ ពូជសាសន៍ សាសនា ឬការរើសអើងផ្សេងទៀត។

ក្រុមហ៊ុនរបស់យើងរំពឹងថាភាគីពាក់ព័ន្ធខាងក្នុងទាំងអស់ - ម្ចាស់ ម្ចាស់ភាគហ៊ុន អ្នកគ្រប់គ្រង និងនិយោជិត - គោរពតាមស្តង់ដារតឹងរ៉ឹងបំផុតនៃការមិនចូលរួម និងមិនគាំទ្ររាល់ការរំលោភលើគោលនយោបាយជ្រើសរើសបុគ្គលិករបស់យើងគ្រប់ពេលវេលា នៅកន្លែងធ្វើការ និងក្នុងជីវិតផ្ទាល់ខ្លួនរបស់ពួកគេ។ ដូចគ្នានេះដែរ ក្រុមហ៊ុនរបស់យើងរំពឹងថាភាគីពាក់ព័ន្ធខាងក្រៅទាំងអស់- អ្នកផ្គត់ផ្គង់ អ្នកម៉ៅការបន្ត

ឈ្មួញកណ្តាល ភ្នាក់ងារ ជាពិសេសភ្នាក់ងារជ្រើសរើសបុគ្គលិក។ សហគ្រាសស្ថាប័ន ឬសហគមន៍ដែលយើងដោះស្រាយជាមួយ - ដើម្បីអនុវត្តន៍តាមគោលនយោបាយ និងមុខតំណែងរបស់ក្រុមហ៊ុនយើងស្តីពីការជ្រើសរើសបុគ្គលិកប្រកបដោយយុត្តិធម៌ និងការទទួលខុសត្រូវ។

ក្រុមហ៊ុនរបស់យើងរំពឹងថាអ្នកពាក់ព័ន្ធទាំងអស់របស់យើងនឹងរក្សាបាននូវការអនុវត្តន៍ស្តង់ដារនៃតម្លាភាព និងគណនេយ្យភាពនៅក្នុងសកម្មភាពរបស់ពួកគេយ៉ាងមុតមាំ។

**ទំនួលខុសត្រូវក្នុងការអនុវត្ត និងដំណោះស្រាយវិសមភាពដែលអាចកើតមាន**

ក្នុងការទទួលស្គាល់ភាពងាយរងគ្រោះនៃក្រុមភាគីពាក់ព័ន្ធមួយចំនួន ដូចជា ពលករចំណាកស្រុក ស្ត្រី និងកូនរបស់ពួកគេ ស្ត្រីមានផ្ទៃពោះ ជនពិការ និងក្រុមផ្សេងទៀតដែលទទួលរងនូវការរើសអើង និងមិនស្មើភាព ក្រុមហ៊ុនរបស់យើងប្តេជ្ញាផ្តល់ការពិចារណាជាពិសេស និងផ្តល់ធនធានដែលស្របតាមតម្លៃក្រុមហ៊ុនរបស់យើង និងស្របតាមសមត្ថភាពរបស់ក្រុមហ៊ុន។ ការអនុលោមតាមគោលនយោបាយនេះនឹងត្រូវបានដឹកនាំដោយនីតិវិធីអនុវត្តគោលនយោបាយដែលលើកកម្ពស់ការយល់ដឹង បង្កើនការការពារ បើកការទទួល ការរាយការណ៍សម្ងាត់ និងការការពារដល់អ្នកផ្តល់ព័ត៌មាន ផ្តល់បណ្តាញសារទុក្ខ និងជម្រើសដោះស្រាយ តាមដាន និងផ្ទៀងផ្ទាត់ថាយុទ្ធសាស្ត្រទាំងអស់នេះកំពុងដោះស្រាយជាប្រព័ន្ធនូវវិសមភាពដែលអាចកើតមាន ក៏ដូចជា សម្របសម្រួលកិច្ចខិតខំប្រឹងប្រែងដើម្បីអនុវត្តគោលនយោបាយជ្រើសរើសបុគ្គលិកប្រកបដោយទំនួលខុសត្រូវ ដែលអាចកាត់បន្ថយ សម្រាល ដល់ការពារហានិភ័យការងារដល់ភាគីពាក់ព័ន្ធទាំងអស់ រួមទាំងកម្មករដែលងាយរងគ្រោះផងដែរ។

សូមជូនដំណឹងថា គោលនយោបាយនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

.....................................

( )

នាយកគ្រប់គ្រង

កាលបរិច្ឆេទ: ___________________